ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

*សំណុំរឿង ព្រហ្មទណ្ឌ*
**លេខ: ៦៣៧**
*ចុះថ្ងៃទី ១៧/៧/២០១៣*
**សាលដីកា**
*លេខ: ២៤ ក្រ.៧ "ច"*
*ចុះថ្ងៃទី ០៩/៤/២០១៤*

# តាមនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ:០៦ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១៤ ដោយមាន ៖

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា.

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

*ដើម្បីជំនុំជម្រះបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ: ៦៣៧ ចុះថ្ងៃទី ១៧/៧/២០១៣ ដែលមាន:*

-ជនជាប់ចោទឈ្មោះ [redacted] បូរត្ន័ ភេទប្រុស អាយុ ៤០ឆ្នាំ ជាតិខ្មែរ មុខរបរ "ក្រឡាបញ្ជី" កើតនៅភូមិពិរាម ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ។ មុនពេលឃុំខ្លួនផ្ទះលេ[redacted] ខណ្ឌឫស្សី កែវ រាជធានីភ្នំពេញ. ប្រពន្ធឈ្មោះ [redacted] (មានកូន ១នាក់) ។ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ។ (ទោសពីមុនគ្មាន)

ចាប់ខ្លួន និងឃុំខ្លួនថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១២ ។***បច្ចុប្បន្ន:*** ឃុំខ្លួននៅពន្ធនាគារ "ម១"

***ជាប់ចោទពីបទ:*** រំលោភលើទំនុកចិត្ត ដោយអ្នករាជការសាធារណៈនៅក្នុងក្របខណ្ឌនៃមុខងាររបស់ខ្លួន និង***បទ:*** ក្លែងបន្លំ ប្រព្រឹត្តនៅរាជធានីភ្នំពេញ ក្នុងអំឡុងឆ្នាំ ២០១០-២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៩១,៣៩៤,៦២៦ និងមាត្រា ៦២៧ នៃក្រមព្រហ្មទណ្ឌ ។

-***មេធាវី:*** លោក [redacted]វិសាល

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]សាខន ភេទប្រុស ជាតិខ្មែរ ឆ្នាំកំណើត ១០/៣/១៩៥៦។ កើតនៅភូមិអូរតាទាត់ ឃុំសំរ៉ុង ស្រុកព្រៃនប់ ខេត្តកំពត ។ ទីលំនៅសព្វថ្ងៃ[redacted] ខណ្ឌចំការមន រាជធានីភ្នំពេញ ។ប្រពន្ធឈ្មោ[redacted] មានកូន ២នាក់ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លីង

-***មេធាវី:*** លោក [redacted]សម្បត្តិ

***<u>អំពើប្រព្រឹត្តរបស់ជនជាប់ចោទ</u>***

នៅអំឡុងឆ្នាំ ២០១០,និងឆ្នាំ ២០១១ ឈ្មោះ [redacted]បូរត្ន័ ( មុខងារ [redacted] ) បំរើការងារនៅសាលាដំបូង

ផ្លូវសម្តេចសុធារស សាលាឧទ្ធរណ៍-មហាអយ្យការ (ទល់មុខព្រះបរមរាជវាំង ក្នុងបរិវេណក្រសួងយុត្តិធម៌)



Scanned with CamScanner

រាជធានីភ្នំពេញ បានទទួលប្រាក់ចំនួន ៦លើក ស្មើនឹង ២៥០.០០០$ (ពីររយហាសិបពាន់ដុល្លាអាមេរិក) ពីលោក [redacted] អៀវហេង (មេធាវីតំណាងដោយអាណត្តិ)ឲ្យឈ្មោះ [redacted] ចុងយ៉េ ហៅ ជាង ញឹប ដើម្បីដាក់តម្កល់ដោះបន្ទុករំលោះផ្ទះចំនួន១០ល្វែង នៅក្នុងបុរីស៊ីធីហោស ដែលត្រូវបានហាមឃាត់តាមដីកាសម្រេចលេខៈ០៥"ញ" ចុះថ្ងៃទី ០៩/១០/២០០៧ របស់សាលាឧទ្ធរណ៍ តាមកំណត់ហេតុប្រគល់ទទួលប្រាក់ដូចខាងក្រោមៈ

-លើកទី ១ ថ្ងៃទី ១១/៦/២០១០ ចំនួន ៧៥.០០០$ (ចិតសិបប្រាំពាន់ដុល្លាអាមេរិក).

-លើកទី ២ ថ្ងៃទី ០៣/៩/២០១០ ចំនួន ២៥.០០០$ (ម្ភៃប្រាំពាន់ដុល្លាអាមេរិក).

-លើកទី ៣ ថ្ងៃទី ០៤/១០/២០១០ ចំនួន ២៥.០០០$ (ម្ភៃប្រាំពាន់ដុល្លាអាមេរិក).

-លើកទី ៤ ថ្ងៃទី ១៥/១២/២០១០ ចំនួន ២៥.០០០$ (ម្ភៃប្រាំពាន់ដុល្លាអាមេរិក).

-លើកទី ៥ ថ្ងៃទី ០៧/៦/២០១១ ចំនួន ៥០.០០០$ (ហាសិបពាន់ដុល្លាអាមេរិក).

-លើកទី ៦ ថ្ងៃទី ២៩/៧/២០១១ ចំនួន ៥០.០០០$ (ហាសិបពាន់ដុល្លាអាមេរិក).

ក្រោយពីបានទទួលប្រាក់ទាំងនេះហើយឈ្មោះ [redacted] បូរ៉ត្នី ពុំបានយកមកតម្កល់ក្នុងគណនីរបស់សាលាដំបូងរាជធានីភ្នំពេញឡើយ បែរជាយកប្រាក់ខាងលើនេះទៅប្រើប្រាស់ផ្ទាល់ខ្លួន រហូតដល់លោក [redacted] គឹមយូ (មេធាវីតំណាងដោយអាណត្តិ) ឲ្យឈ្មោះ [redacted] ស៊ុន និងលោក [redacted] អៀវហេង (មេធាវីតំណាងដោយអាណត្តិ) ឲ្យឈ្មោះ [redacted] ចុងយ៉េ ហៅ [redacted] ញឹប បានព្រមព្រៀងគ្នាបញ្ចប់រឿងក្ដីនេះ ហើយត្រូវប្រគល់ទទួលប្រាក់តម្កល់ចំនួន ២៥០.០០០$ (ពីររយហាសិបពាន់ដុល្លាអាមេរិក) ឲ្យទៅឈ្មោះ [redacted] ស៊ុន ដែលជាម្ចាស់បំណុលវិញ ទើបដឹងថាប្រាក់នេះមិនមាននៅក្នុងគណនីរបស់សាលាដំបូងរាជធានីភ្នំពេញ ឡើយលោកចៅក្រម [redacted] សាខន ក៏បានប្ដឹងឈ្មោះ [redacted] បូរ៉ត្នី ពីបទៈ ក្លែងហត្ថលេខារបស់ខ្លួនក្នុងកំណត់ហេតុប្រគល់ទទួលប្រាក់ និងដីកាសម្រេចឲ្យលក់ផ្ទះល្វែងក្នុងសំណុំរឿង រក្សាការពារ ដែលមានលោក [redacted] គឹមយូ (មេធាវីតំណាងដោយអាណត្តិ) ឲ្យម្ចាស់បំណុល និងលោក [redacted] អៀវហេង (មេធាវីតំណាងដោយអាណត្តិ)ឲ្យកូនបំណុល ។

*-រឿងនេះសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចសេចក្ដីតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ៤៧ "ជ" ចុះថ្ងៃទី ៣០/ឧសភា/២០១៣ ដែលមានខ្លឹមសារដូចតទៅ៖*

I/ឲ្យឈ្មោះ [redacted] បូរ៉ត្ន ភេទប្រុស អាយុ ៤១ឆ្នាំ រួចខ្លួនពីបទចោទ ពីបទៈ ក្លែងបន្លំ ប្រព្រឹត្តនៅរាជធានីភ្នំពេញក្នុងអំឡុងឆ្នាំ ២០១០ និងឆ្នាំ ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា ៦២៦ , មាត្រា ៦២៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

II/ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] បូរ៉ត្ន ភេទប្រុស អាយុ ៤១ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៤ឆ្នាំ និង ០៦ខែ (បួនឆ្នាំ និង ប្រាំមួយខែ) ពីបទៈ រំលោភលើទំនុកចិត្តដោយអ្នករាជការសាធារណៈនៅក្នុងក្របខណ្ឌនៃមុខងាររបស់ខ្លួន ប្រព្រឹត្តនៅរាជធានីភ្នំពេញ នៅក្នុងអំឡុងឆ្នាំ ២០១០ និងឆ្នាំ ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៩៧ មាត្រា ៣៩១ និងមាត្រា ៣៩៤ នៃក្រមព្រហ្មទណ្ឌ ។

III/បង្គាប់ឲ្យឈ្មោះ [redacted] បូរ៉ត្ន សងប្រាក់ចំនួន ២៥០.០០០$ (ម្ភៃប្រាំម៉ឺនដុល្លារអាមេរិក) ឲ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ុន ឬ ស៊ុន លីង ភេទស្រី (កើតថ្ងៃទី ៤/១១/១៩៦៨) ជនជាតិចិន មុខរបរទីប្រឹក្សាក្រុមហ៊ុន ដែលកាន់លិខិតឆ្លងដែនលេខ G 26333620 មានអាស័យដ្ឋាន ROOM E 26F Nº 1388 WUDING XI ROAD, SHANGHAI CHINA ដែលជាទាយាទរបស់សពឈ្មោះ ZHI ZHENG SUN ។

IV/សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០៩ខែមេសា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាខន ,ឈ្មោះ [redacted] ស៊ុន (LING SUN) ចំពោះមុខមេធាវីការ ពារសិទ្ធិឲ្យ ជនជាប់ចោទ ចំពោះ មុខមេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណីចាត់ទុកជាចំពោះមុខ និងប្រកាសជាសាធារណៈថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ២០១៣ ។ បើកផ្លូវប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញ សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខៈ ៤០៤ ចុះថ្ងៃទី ០៤/៦/២០១៣ របស់ជនជាប់ចោទឈ្មោះ



Scanned with CamScanner

[redacted] បុរ័ត្ន ប្តឹងឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខ: ៤៧ "ជ" ចុះថ្ងៃទី ៣០/ឧសភា/២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

-បានឃើញរបាយការណ៍របស់ចៅក្រមរបាយការណ៍ចុះថ្ងៃទី ៣០/៨/២០១៣ ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការចុះថ្ងៃទី ០១/១០/២០១៣ ។

## នាពេលសវនាការ

### ចៅក្រមអានរបាយការណ៍សង្ខេបអង្គហេតុ

*-មេធាវី:* លោក[redacted]វិសាល បានស្នើសុំឲ្យតុលាការបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន ព្រោះការផ្តន្ទាទោសនេះមានលក្ខណៈអតិបរមានៃទោស ក្នុងរឿងនេះប្រសិនបើកូនក្តីខ្ញុំបាទបានចេញនៅក្រៅឃុំ កូនក្តីខ្ញុំ នឹងរកប្រាក់មកសងឲ្យដើមបណ្តឹងវិញ ។

*-មេធាវី:* លោក[redacted]សម្បត្តិ

បានតវ៉ាជំទាស់ នូវការលើកឡើងរបស់លោកមេធាវី [redacted]វិសាល ថា:សុំឲ្យតុលាការបន្ធូរបន្ថយទោសដល់ជនជាប់ចោទឈ្មោះ [redacted] បុរ័ត្ន ក្នុងការសុំឲ្យតុលាការបន្ធូរបន្ថយទោសដល់ជនជាប់ចោទបែបនេះ តើលោកមេធាវីសំអាងទៅលើមាត្រាណា ? ដែលអាចសុំឲ្យតុលាការបន្ធូរបន្ថយទោស ។ ចំពោះដីកាសម្រេចរក្សាការពារហាមឃាត់ផ្ទះជនជាប់ចោទនោះ ជនជាប់ចោទបានផ្ទេរផ្ទះនេះទៅឲ្យម្តាយរបស់គាត់ទៅហើយ ។

### សេចក្តីសន្និដ្ឋានតំណាងមហាអយ្យការ

-ជនជាប់ចោទឈ្មោះ [redacted] បុរ័ត្ន បានប្តឹងឧទ្ធរណ៍តែនាពេលសវនាការនេះគាត់បានទទួលដំណឹងហើយ តែពេលនេះគាត់មានជម្ងឺ មិនអាចមកចូលរួមសវនាការបានទេ។ហេតុដូច្នេះតុលាការអាចសម្រេចសេចក្តី នឹងផ្តន្ទាទោសទៅលើជនជាប់ចោទទៅតាមនីតិវិធីបាន ។

-ទឹកប្រាក់ដែលមានការពាក់ពន្ធ័នេះគឺជាប្រាក់តម្កល់ ដូច្នេះគប្បីជនជាប់ចោទយកប្រាក់នេះទៅដាក់តម្កល់នៅក្នុងគណនីតុលាការ មិនត្រូវយកប្រាក់នេះទៅប្រើប្រាស់ផ្ទាល់ខ្លួនឡើយ ។

-មហាអយ្យការយល់ថា:ជនជាប់ចោទមានពិរុទ្ធភាពគ្រប់គ្រាន់ នឹងដើម្បីផ្តន្ទាទោសទៅលើជនជាប់ចោទរូបនេះបានហើយ ។

-មហាអយ្យការសុំឲ្យក្រុមប្រឹក្សាពិនិត្យ និងពិចារណាតាមច្បាប់ ។

### សេចក្តីសន្និដ្ឋានមេធាវី

ខ្ញុំបាទឈ្មោះ[redacted]វិសាល មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ[redacted]បុរ័ត្ន សូមធ្វើសេចក្តីសន្និដ្ឋានដូចតទៅ៖

-កូនក្តីខ្ញុំបាទជាក្រឡាបញ្ជីដែលបានបំពេការងារនៅតុលាការសាលាដំបូងរាជធានីភ្នំពេញអស់រយៈពេលយូរឆ្នាំមកហើយ ក្នុងនាមខ្ញុំបាទជាមេធាវីការពារឲ្យជនជាប់ចោទ សុំឲ្យក្រុមប្រឹក្សាពិចារណា កូនក្តីខ្ញុំបាទគ្រាន់តែជាក្រឡាបញ្ជីពុំមានសិទ្ធិសម្រេចអ្វីទេ តើមានលទ្ធភាពអ្វីដែលហ៊ានទទួលប្រាក់ជំនួសលោកចៅក្រម[redacted]សាខន នោះ ។ តាមពិតកូនក្តីខ្ញុំបាទបានចាញ់បោកលោកចៅក្រម[redacted]សាខន ទៅវិញទេ ។ ក្នុងឯកសារនោះមានហត្ថលេខារបស់លោកចៅក្រម[redacted]សាខន យ៉ាងច្បាស់ ។

-នៅចៅក្រមស៊ើបលោក[redacted]សាខន បានបដិសេធមិនទទួលស្គាល់ក្នុងការទទួលប្រាក់តម្កល់នេះទេ ហើយឲ្យកូនក្តីខ្ញុំបាទទទួលកំហុសនេះតែម្នាក់ឯង ។

-ការទទួលប្រាក់ចំនួន ៦លើកនេះកូនក្តីខ្ញុំបាទនៅតែទទួលស្គាល់ប្រាក់ចំនួន ៧៥.០០០$ដដែល ។

-ផ្ទះរបស់របស់កូនក្តីខ្ញុំបាទត្រូវបានតុលាការហាមឃាត់ ក្នុងសំណុំរឿងរក្សាការពារ ទៅហើយ,ហើយផ្ទះនេះ គឺមានតម្លៃរហូតដល់ ១០០.០០០$ ឯណោះ ។

### សេចក្តីសន្និដ្ឋានមេធាវី

លោក[redacted]សម្បត្តិ

-ក្នុងសំណុំរឿងនេះ គឺមានពីរ ដំបូងជារឿងរដ្ឋប្បវេណី គឺកើតឡើងពីការរកស៊ីលក់ដី,ឪពុករបស់កូនក្តីខ្ញុំបាទ គឺ

គាត់មានអចលនវត្ថុនៅក្នុងប្រទេសកម្ពុជា ហើយគាត់បានប្តឹងទៅតុលាការដើម្បីផ្ទេរ អចលនវត្ថុនេះមកឲ្យកូនក្តីខ្ញុំបាទ ក្នុងរឿងនេះគឺតម្រូវឲ្យមានការដាក់ប្រាក់តម្កល់នៅតុលាការ ។

-ជនជាប់ចោទនេះបានទទួលប្រាក់ចំនួន ៦លើក ដែលមានចំនួនទឹកប្រាក់ ២៥០.០០០$ (ពីររយហាសិបពាន់ដុល្លាអាមេរិក)ពេលនោះគាត់បានទទួល ,តែក្រោយមកគាត់ទទួលស្គាល់តែ ៧៥.០០០$(ចិតសិបប្រាំពាន់ដុល្លាអាមេរិក)ទេ ។ ដូច្នេះប្រាក់នេះ គឺមានការបាត់បង់មិនដឹងទៅណាទេ ។

-ចំពោះទោសដែលតុលាការបានសម្រេចផ្តន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩៤ នោះ បើមានចំណុចណា អាចផ្តល់ស្ថានសម្រាលបាននោះ ខ្ញុំបាទជាមេធាវីសុំឲ្យតុលាការពិចារណា ។

-ចំពោះប្រាក់ ២៥០.០០០$ នោះគឺជនជាប់ចោទបានយកទៅប្រើប្រាស់ផ្ទាល់ខ្លួនដូចមហាអយ្យការបានលើកឡើងមែន ។

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានតំណាងមហាអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារជនជាប់ចោទ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីដើមបណ្តឹង
-ក្រោយពីបានពិនិត្យគ្រប់ឯកសារ និងភស្តុតាងផ្សេងៗ
-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់

## សាលាឧទ្ធរណ៍
## យល់ឃើញថា

១-ពាក្យបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] បូរ័ត្ន ចុះថ្ងៃទី ០៣-៦-២០១៣ ប្តឹងឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៧ "ជ" ចុះថ្ងៃទី ៣០-៥-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់សេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

២-ជនជាប់ចោទឈ្មោះ [redacted] បូរ័ត្ន បានទទួលដំណឹងពីកាលបរិច្ឆេទសវនាការដេញដោលជាសាធារណៈហើយ ប៉ុន្តែមិនបានចូលរួម ហេតុនេះសាលាឧទ្ធរណ៍ បន្តនីតិវិធីសវនាការ ដោយចាត់ទុកជាចំពោះមុខជនជាប់ចោទ ។

៣-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បូរ័ត្ន ដែលបានឆ្លើយនៅដំណាក់កាលអយ្យការថា: ខ្លួនពិតជាបានទទួលប្រាក់ចំនួន ២៥០.០០០$ ( ពីររយហាសិបពាន់ដុល្លារអាមេរិក ) ពីលោកមេធាវី [redacted] អៀវហេង ពិតប្រាកដមែន,បន្ទាប់ពីទទួលបានប្រាក់ ខ្លួនបានប្រាប់លោកចៅក្រម [redacted] សាខន ហើយគាត់បានឲ្យខ្លួនយកទៅដាក់នៅក្នុងគណនីតុលាការ តែខ្លួនបានបង្វែរប្រាក់នោះយកទៅប្រើប្រាស់ផ្ទាល់ខ្លួនជាបណ្តោះអាសន្នសិន (ឯ/២៦) ។

ចម្លើយសារភាពនេះ ស៊ីសង្វាក់ទៅនឹងចម្លើយសាក្សីលោកមេធាវី [redacted] អៀវហេង តំណាងដោយអាណត្តិឲ្យឈ្មោះ [redacted] ស៊ុន ហៅ [redacted] ញឹប បានឆ្លើយនៅចៅក្រមស៊ើបសួរប្រហាក់ប្រហែលគ្នាថា: ខ្លួនបានចុះហត្ថលេខា លើកំណត់ហេតុទទួលប្រាក់ចំនួន ៦លើក សរុបទឹកប្រាក់ចំនួន ២៥០.០០០$ (ពីររយហាសិបពាន់ដុល្លារអាមេរិក) ហើយខ្លួនបានប្រគល់ប្រាក់ទៅឲ្យឈ្មោះ [redacted] បូរ័ត្ន ដោយពុំបានដឹងថាប្រាក់នោះឈ្មោះ [redacted] បូរ័ត្ន យកទៅចាយទេ (ឯ/៣៨) និងមានលក្ខណៈស្របគ្នាទៅនឹងចម្លើយរបស់សាក្សីឈ្មោះ [redacted] បុភា ជានាយកក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ ដែលបានឆ្លើយនៅចៅក្រមស៊ើបសួរថា: ការប្រគល់ប្រាក់ទៅឲ្យក្រឡាបញ្ជីឈ្មោះ [redacted] បូរ័ត្ន ទាំង ៦ លើកនោះ ខ្លួនមិនបានដឹងទេ ហើយខ្លួនក៏មិនបានទទួលប្រាក់ទាំងនោះមកតម្កល់ទុកនៅគណនីរបស់សាលាដំបូងរាជធានីភ្នំពេញដែរ (ឯកសារលេខ ៤២) ។

ម្យ៉ាងទៀតបើទោះបីជាជនជាប់ចោទឈ្មោះ [redacted] បូរ័ត្ន បានឆ្លើយបដិសេធនៅសវនាការសាលាដំបូងថា : ខ្លួន បានយកប្រាក់ត្រឹម ៧៥.០០០$ (ចិតសិបប្រាំពាន់ដុល្លារអាមេរិក) ហើយបានប្រគល់ប្រាក់ចំនួន ១៧៥.០០០$ (មួយរយចិតសិបប្រាំពាន់ដុល្លារអាមេរិក) ទៀតឲ្យលោកចៅក្រម [redacted] សាខន (ឯកសារលេខ១១១) ប៉ុន្តែចម្លើយដោះសារនេះ មិនមានមូលដ្ឋានឲ្យក្រុមប្រឹក្សាជឿបានទេ ដោយហេតុថា:មិនមានភស្តុតាងគ្រប់គ្រាន់ដែលអាចបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] បូរ័ត្ន បានយកប្រាក់ចំនួន ១៧៥.០០០$(មួយរយចិតសិបប្រាំពាន់ដុល្លារអាមេរិក) ទៅឲ្យលោកចៅក្រម [redacted] សាខន ទេ ។ ផ្ទុយទៅវិញមានតែលោកចៅក្រម [redacted] សាខន ដែលបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងឈ្មោះ [redacted] បូរ័ត្ន ពីបទក្លែងបន្លំហត្ថលេខារបស់ខ្លួន (ឯកសារលេខ៣៦) ហើយក៏ស៊ីសង្វាក់ទៅនឹងចម្លើយរបស់សាក្សីឈ្មោះ [redacted]មករា ដែលជាជំនួយការរបស់ឈ្មោះ [redacted] បូរ័ត្ន ដែលបានឆ្លើយថា ចំពោះកំណត់ហេតុទទួលប្រាក់ទាំង ៥ ខ្លួនពុំដែលបានយកទៅឲ្យលោកចៅក្រម [redacted] សាខន ចុះហត្ថលេខាទេ (ឯកសារលេខ៤៨)។ នេះ សបញ្ជាក់ឲ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] បូរ័ត្ន ពិតជាបានយកប្រាក់ដែលឈ្មោះ [redacted] ស៊ុន ហៅ [redacted] ញឹប បានតម្កល់ក្នុងសំណុំរឿងក្តីដែលខ្លួនទទួលបន្ទុក យកទៅប្រើប្រាស់ផ្ទាល់ខ្លួន ដោយមិនបានតម្កល់ទុកក្នុងគណនីរបស់សាលាដំបូងរាជធានីភ្នំពេញពិតប្រាកដមែន ដែលនេះជាអំពើ *វិលោភលើទំនុកចិត្ត ដោយអ្នករាជការសាធារណៈ នៅក្នុងក្របខណ្ឌនៃមុខងាររបស់ខ្លួន* ស្របតាមមាត្រា ៣៩១ និងមាត្រា ៣៩៤ នៃក្រមព្រហ្មទណ្ឌ ។

៤-តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បានសន្និដ្ឋានថា:មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] បូរ័ត្ន *ពីបទៈ វិលោភលើទំនុកចិត្ត ដោយអ្នករាជការសាធារណៈ នៅក្នុងក្របខណ្ឌនៃមុខងាររបស់ខ្លួន* ស្របតាមមាត្រា ៣៩១ និងមាត្រា ៣៩៤ នៃក្រមព្រហ្មទណ្ឌ ប៉ុន្តែដោយសារច្បាប់កំណត់ផ្តន្ទាទោសចាប់ពី ២ឆ្នាំ-៥ឆ្នាំ ហេតុនេះសុំឲ្យសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ពិនិត្យ និងសម្រេចតាមច្បាប់ ។ គប្បីក្រុមប្រឹក្សាពិចារណា ។

៥-លោកមេធាវី [redacted]សម្បត្តិ មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ុង ហៅ [redacted] ញឹប បានសន្និដ្ឋានសំណូមពរឲ្យសាលាឧទ្ធរណ៍សម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងទុកជាបានការ ។ គប្បីក្រុមប្រឹក្សាពិចារណា ។

៦-លោក [redacted] វិសាល មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានសន្និដ្ឋានសំណូមពរឲ្យសាលាឧទ្ធរណ៍សម្រេចបន្ធូរបន្ថយទោសឲ្យកូនក្តីខ្លួន ដោយហេតុថាកូនក្តីខ្លួនបានឆ្លើយសារភាពកំហុស ហើយម្យ៉ាងទៀតកូនក្តីខ្លួនមានជម្ងឺប្រចាំកាយ និងមានឪពុកម្តាយចាស់ជរាត្រូវការអ្នកមើលថែ។ក្រុមប្រឹក្សាយល់ថា:ជនជាប់ចោទឈ្មោ[redacted] បូរ័ត្ន ពិតជាបានសារភាពទទួលកំហុសរបស់ខ្លួន ក្នុងការបង្វេរប្រាក់ដែលតម្កល់ក្នុងសំណុំរឿងក្តី ដែលខ្លួនទទួលបន្ទុក ទៅប្រើប្រាស់ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនប្រាកដមែន ។ ការសារភាពនេះបញ្ជាក់អំពី ការភ្ញាក់រលឹកដឹងពីកំហុសរបស់ខ្លួន ដែលគប្បីក្រុមប្រឹក្សាពិចារណាពីស្ថានសម្រាលទោសខ្លះដល់ជនជាប់ចោទតាមមាត្រា ៩៣ និងមាត្រា ៩៤ ដើម្បីជាគម្រូដល់ជនជាប់ចោទដទៃទៀត ដែលចេះភ្ញាក់រលឹក ដឹងពីកំហុសរបស់ខ្លួនដែលប្រព្រឹត្តល្មើសនឹងច្បាប់ ។

៧-សាលក្រមព្រហ្មទណ្ឌលេខ ៤៧ "ជ" ចុះថ្ងៃទី ៣០-៥-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ គប្បីតម្កល់ទុកជាបានការ លើកលែងតែចំណុចទណ្ឌកម្មដែលគប្បីពិចារណាតាមការយល់ឃើញខាងលើ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] បូរ័ត្ន ចុះថ្ងៃទី ០៣-៦-២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ខ្លះ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៧-ជ-ចុះថ្ងៃទី ៣០-៥-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល លើកលែងតែចំណុចទី॥ នៃវិនិច្ឆ័យសេចក្តីត្រង់ " ផ្តន្ទាទោសលើឈ្មោះ [redacted] បូរ័ត្ន ដាក់ពន្ធនាគារកំណត់ ៤ឆ្នាំ និង ៦ខែ (បួនឆ្នាំ និងប្រាំមួយខែ) " ត្រូវកែប្រែមកជា " ផ្តន្ទាទោសឈ្មោះ [redacted] បូរ័ត្ន ដាក់ពន្ធនាគារ



Scanned with CamScanner

កំណត់ ៤ឆ្នាំ និង ៦ខែ (បួនឆ្នាំ និងប្រាំមួយខែ) តែទោសនេះត្រូវអនុវត្តទោសគុកចំនួន ៣ឆ្នាំ(បី) ហើយទោសនៅសល់ពីនេះ ត្រូវអនុវត្តទោសព្យួរធម្មតា *គឺបង្ខំ: រំលោភលើទំនុកចិត្ត ដោយអ្នករាជការសាធារណៈ នៅក្នុងក្របខណ្ឌនៃមុខងាររបស់ខ្លួន* តាមមាត្រា ៣៩១,៣៩៤, ៩៣,៩៤,៩៧ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ វិញ ។

ចំណុចក្រៅពីនេះត្រូវរក្សាទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធីច្បាប់ ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ២៤-៣-២០១៨ ចំពោះមុខមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ កំបាំងមុខជនជាប់ចោទ តែចាត់ទុកជាចំពោះមុខ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ០៩-៤-២០១៨ ។

ទុកសិទ្ធិប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។/

*សេចក្ដីនេះព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មក មន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់គ្រប់តំណែងនិងកងកម្លាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។*

*(សាលដីកានេះ ចូលជាស្ថាពរ អំពីទោស រីឯសំណងរដ្ឋប្បវេណី ជាប់បណ្ដឹងសាទុក្ខ).*

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| លោក [redacted] | លោក [redacted] -លោ[redacted] | លោក [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍ថ្ងៃទី.០៦ ខែ.៦. ឆ្នាំ ២០១៨

ក្រឡាបញ្ជីសវនាការ

[redacted]

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]



Scanned with CamScanner